# زيارة عاشوراء

غَيْرَ راغِبٍ عَنْكُما وَلا مِنْ زِيارَتِكُما بَلْ راجِعٌ عائِدٌ إِنْ شاءَ اللهُ وَلا حَوْلَ وَلا قُوَّةَ إِلَّا بِاللهِ ،

ជិនណាយព្រះអង្គទាំងពីរឡើយ ដោយមិនធុញទ្រាន់ស៊ីរ៉ាស់ព្រះអង្គទាំងពីរឡើយ តែទូលព្រះបង្គំជាខ្ញុំនឹងត្រឡប់មកស៊ីរ៉ាស់ព្រះអង្គទាំងពីរعليهم السلامវិញ អាស្រ័យលើព្រះបំណងអល់ឡោះហ្ម៍عز وجل ពុំមានកម្លាំងនិងឥទ្ធិពលក្រៅពីអាស្រ័យលើអល់ឡោះហ្ម៍عز وجل ឡើយ ។

يا سادَتِي رَغِبْتُ إِلَيْكُما وَإِلَى زِيارَتِكُما بَعْدَ أَنْ زَهِدَ فِيكُما وَفِي زِيارَتِكُما أَهْلُ الدُّنْيا

ព្រះរាជអគ្គនាយកទូលព្រះបង្គំអើយ ទូលព្រះបង្គំស្រឡាញ់ព្រះអង្គទាំងពីរعليهم السلام ទូលព្រះបង្គំចង់ស៊ីរ៉ាស់ព្រះអង្គទាំងពីរعليهم السلام ខណៈដែលមនុស្សលោកនេះបោះបង់ចោលព្រះអង្គទាំងពីរعليهم السلام ហើយលែងស៊ីរ៉ាស់ព្រះអង្គទាំងពីរعليهم السلام

فَلا خَيَّبَنِيَ اللهُ مِمَّا رَجَوْتُ وَما أَمَّلْتُ فِي زِيارَتِكُما إِنَّهُ قَرِيبٌ مُجِيبٌ.

សូមកុំឲ្យអល់ឡោះហ្ម៍عز وجلធ្វើឲ្យទូលព្រះបង្គំខានបានអ្វីដែលទូលព្រះបង្គំសង្ឃឹមបាន និងអ្វីដែលទូលព្រះបង្គំប៉ងប្រាថ្នាពេលមកស៊ីរ៉ាស់ព្រះអង្គទាំងពីរនោះ ព្រោះព្រះអង្គعز وجلនៅជិតបង្កើយ ព្រះអង្គعز وجلធ្វើសមបំណង ។

أَبا عَبْدِ اللهِ يا سَيِّدِي،

អាប់ឌុលឡោះហ៊ صلوات الله عليه والسلام ព្រះអគ្គនាយក ទូលព្រះបង្គំអើយ

وَسَلامِي عَلَيْكُما مُتَّصِلٌ ما اتَّصَلَ اللَّيْلُ وَالنَّهارُ واصِلٌ ذَلِكَ إِلَيْكُما غَيْرُ مَحْجُوبٍ عَنْكُما سَلامِي إِنْ شاءَ اللهُ،

សូមឲ្យពរជ័យសិរីសួស្តីរបស់ទូលព្រះបង្គំជាខ្ញុំបានលើព្រះអង្គ عليهم السلام ទាំងពីររៀងដរាបដរាបណានៅមានយប់និងថ្ងៃ សូមឲ្យពរជ័យសិរីសួស្តីរបស់ទូលព្រះបង្គំ តាមទៅដល់ព្រះអង្គទាំងពីរ عليهم السلام ជាអនន្ត សូមកុំឲ្យពរជ័យសិរីសួស្តីរបស់ទូលព្រះបង្គំអាក់ខានទៅដល់ព្រះអង្គទាំងពីរឡើយ អាស្រ័យលើព្រះបំណងអល់ឡោះហ៊ عز وجل

وَأَسْأَلُهُ بِحَقِّكُما أَنْ يَشاءَ ذَلِكَ وَيَفْعَلَ فَإِنَّهُ حَمِيدٌ مَجِيدٌ،

ទូលព្រះបង្គំសូមអល់ឡោះហ៊ عز وجل ក្នុងនាមព្រះរាជសិទ្ធិព្រះអង្គទាំងពីរ عليهم السلام សូមឲ្យអល់ឡោះហ៊ عز وجل ទ្រង់ព្រះមេត្តាមានព្រះបំណងដូច្នេះ ហើយធ្វើដូច្នេះ ព្រោះព្រះអង្គ عز وجل សក្តិសមជាទីកោតសរសើរមែន ។

انْقَلَبْتُ يا سَيِّدَيَّ عَنْكُما تائِبًا حامِدًا لِلّهِ شاكِرًا راجِيًا لِلْإِجابَةِ غَيْرَ آيِسٍ وَلا قانِطٍ آيِبًا

ទូលព្រះបង្គំសូមគោរពលាព្រះអង្គទាំងពីរត្រឡប់វិញ ឱព្រះរាជអគ្គនាយកទូលព្រះបង្គំអើយ ដោយរាងចាលកំហុស ដោយគោរពសក្ការៈអល់ឡោះហ៊ عز وجل ដោយអរព្រះគុណ ដោយសង្ឃឹមនឹងបានសមបំណង មិនអស់សង្ឃឹម មិនបាក់ទឹកចិត្ត

عائِدًا راجِعًا إِلَى زِيارَتِكُما

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំនឹងត្រឡប់មកស៊ីរ៉ាស់ព្រះអង្គទាំងពីរ عليهم السلام ដោយឥត



قال صالح بن عقبة وسيف بن عميرة : قال علقمة بن محمّد الحضرمي قلت للباقر صَلَواتُ اللهِ وسَلامُهُ عَلَيهِ : علّمني دعاءً أدعو به في ذلك اليوم إذا أنا زرته من قرب ودعاءً أدعو به إذا لم أزره من قرب وأومأت من بعد البلاد ومن داري بالسلامة إليه. فقال لي : يا علقمة إذا أنت صليت الركعتين بعد أن تؤمي إليه بالسلام فقل بعد الايماء إليه من بعد التكبير هذا القول (أي الزيارة الآتية) فإنّك إذا قلت ذلك فقد دعوت بما يدعو به زوّاره من الملائكة وكتب الله لك مائة ألف ألف درجة وكنت كمن استشهدوا معه تشاركهم في درجاتهم ، وما عرفت إلاّ في زمرة الشهداء الذين استشهدوا معه ، وكتب لك ثواب زيارة كل نبيّ وكل رسول وزيارة كل من زار الحسين عليه‌السلام منذ يوم قتل سلام الله عليه وعلى أهل بيته ، تقول :

ស្វ៏ឡាស់ ប៊ិន អ៊ុក្វបាស់ និង សៃហ្វ៍ ប៊ិន អ៊ុម៉ៃរ៉ោះត៍បានថា អាល់ក៏ម៉ាស់ ប៊ិន មូហុាំម៉ាដ់ អាល់-ហាដ់រ៉មីបានថ្លែងថា៖ "ខ្ញុំបានទូល[អ៊ីមុាំ] អាល់-បាគៀរ صلوات الله عليه والسلام ថា៖ "សូមព្រះអង្គ صلوات الله عليه والسلام បង្ហាត់ទូលបង្គំនូវឌូអាអ៊ុំមួយដើម្បីទូលបង្គំសូត្រក្នុងថ្ងៃនេះ ពេលទូលបង្គំស៊ីរ៉ាស់ព្រះអង្គ (គឺអ៊ីមុាំ ហ៊ូសៃន៍ صلوات الله عليه والسلام) នៅឯផ្នូរព្រះអង្គ صلوات الله عليه والسلام និងឌូអាអ៊ុំមួយទៀតដើម្បីទូលបង្គំសូត្របើទូលបង្គំមិនស៊ីរ៉ាស់ព្រះអង្គ صلوات الله عليه والسلام នៅឯផ្នូរព្រះអង្គទេដោយឧទ្ទិសសាឡាមទៅកាន់ព្រះអង្គ صلوات الله عليه والسلام ពីស្រុកនាយ ពីផ្ទះទូលបង្គំ ។" អ៊ីមុាំ صلوات الله عليه والسلام បានប្រាប់ខ្ញុំថា៖ "អាល់ក៏ម៉ាស់អើយ បន្ទាប់ពីបានឧទ្ទិសសាឡាមទៅកាន់ព្រះអង្គ صلوات الله عليه والسلام ហើយ ចូរស្វ៏ឡាត់ពីររ៉ក់អាត់ រួចហើយ បន្ទាប់ពីបានបញ្ជាក់ថា[ស៊ីរ៉ាស់]ពីចម្ងាយហើយបានសូត្រថា الله أكبر ចូរលោកសូត្រដូចនេះ (គឺសូត្រស៊ីយ៉ារ៉ាស់ខាងក្រោមនេះ) ។ បើលោកបានសូត្រដូចនេះ លោកបានបួងសួង[អល់ឡោះហ៊ عز وجل]ដូចអស់ទេវតាបានសូត្រដែរ ពេលអស់ទេវតាទាំងនោះស៊ីរ៉ាស់ព្រះអង្គ صلوات الله عليه والسلام ។ អល់ឡោះហ៊ عز وجل នឹងចារទុកឲ្យលោកនូវ ១០០ ០០០ ០០០ បុណ្យសក្តិ អល់ឡោះហ៊ عز وجل នឹងចាត់ទុកលោកដូចអស់ទុក្ករបុគ្គលដែលបានបូជាជីវិតជាមួយព្រះអង្គ صلوات الله عليه والسلام ដែរ លោកជាសហការី

របស់បុគ្គលទាំងនេះដែលមានលំដាប់ថ្នាក់ខ្ពស់ ។ គេនឹងស្គាល់លោកជាបុគ្គលដែលបានបូជាជីវិត ក្នុងចំណោមទុក្ករបុគ្គលដែលបានបូជាជីវិតជាមួយព្រះអង្គ(صلوات الله عليه والسلام) ។ អល់ឡោះហ៍(عزوجل)នឹងចារទុកឲ្យលោកនូវរង្វាន់ដោយសារស៊ីយ៉ារ៉ាស់របស់ព្រះសាស្តាគ្រប់អង្គ ឬរបស់ព្រះសាសនៈទូតគ្រប់អង្គ និងរបស់បុគ្គលគ្រប់រូបដែលស៊ីរ៉ាស់អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) ចាប់តាំងពីថ្ងៃដែលព្រះអង្គ(صلوات الله عليه والسلام)ទទូលទិវង្គតតរៀងមក ។ ចូរលោកសូត្រថា៖

| | |
|---|---|
| السَّلامُ عَلَيْكَ يا أَبا عَبْدِ اللهِ ، | សូមសិរីសួស្តីកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) ឱ អាប៊ូ អាប់ឌុលឡោះហ៍(صلوات الله عليه والسلام) |
| السَّلامُ عَلَيْكَ يا بْنَ رَسُولِ الله | សូមសិរីសួស្តីកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) ឱ ព្រះរាជបុត្រ(صلوات الله عليه والسلام)របស់ព្រះសាសនៈទូត(صلى الله عليه وآله وسلم) |
| السَّلامُ عَلَيْكَ يا بْنَ أَمِيرِ الْمُؤْمِنِينَ وَابْنَ سَيِّدِ الْوَصِيِّينَ ، | សូមសិរីសួស្តីកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) ឱ ព្រះរាជបុត្រ(صلوات الله عليه والسلام)របស់ព្រះរាជអគ្គមហាប្រមុខ(صلوات الله عليه والسلام)របស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា ឱព្រះរាជប្រមុខរបស់អស់ព្រះទាយាទទាំងឡាយ |
| السَّلامُ عَلَيْكَ يا بْنَ فاطِمَةَ سَيِّدَةِ نِساءِ العالَمِينَ ، | សូមសិរីសួស្តីកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) ឱព្រះរាជបុត្រ(صلوات الله عليه والسلام)របស់ហ្វាទីម៉ាស់(سلام الله عليها) ព្រះរាជនាយិការបស់នារីក្នុងលោកទាំងឡាយ |
| السَّلامُ عَلَيْكَ يا ثارَ اللهِ وَابْنَ | សូមសិរីសួស្តីកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) |



| | |
|---|---|
| مُلْجِئًا ظَهْرِي إِلَى اللهِ مُتَوَكِّلًا عَلَى اللهِ ، | ថ្វាយចិត្តលើអល់ឡោះហ៍(عزوجل) ដោយពឹងផ្អែកលើអល់ឡោះហ៍(عزوجل) ដោយសង្ឃឹមលើអល់ឡោះហ៍(عزوجل) |
| وَأَقُولُ: حَسْبِيَ اللهُ وَكَفى سَمِعَ اللهُ لِمَنْ دَعا لَيْسَ لِي وَراءَ اللهِ وَوَراءَكُمْ يا سادَتِي مُنْتَهى، ما شاءَ رَبِّي كانَ وَما لَمْ يَشَأْ لَمْ يَكُنْ، وَلا حَوْلَ وَلا قُوَّةَ اِلَّا بِاللهِ. | ទូលព្រះសូមថ្លែងថា៖ "អល់ឡោះហ៍(عزوجل) គ្រប់គ្រាន់ណាស់សម្រាប់ទូលព្រះបង្គំ អល់ឡោះហ៍(عزوجل)ទ្រង់សវនាការអ្នកបួងសួងព្រះអង្គ(عزوجل) ។ ក្រៅពីអល់ឡោះហ៍(عزوجل)និងក្រៅព្រះអង្គទាំងអស់(عليهم السلام) ឱព្រះអគ្គប្រមុខ(عليهم السلام)របស់ទូលព្រះបង្គំអើយ ទូលព្រះបង្គំពុំមានទីទុកចិត្តទេ ។ អ្វីដែលព្រះម្ចាស់(عزوجل) ទូលព្រះបង្គំមានព្រះបំណង វានឹងកើតមានឡើង អ្វីដែលព្រះអង្គ(عزوجل)មិនមានព្រះបំណងទេ វានឹងមិនកើតមានឡើងទេ ។ ពុំមានកម្លាំងនិងឥទ្ធិពលក្រៅពីអាស្រ័យលើអល់ឡោះហ៍(عزوجل)ឡើយ ។" |
| اَسْتَوْدِعُكُمَا اللهَ وَلا جَعَلَهُ اللهُ آخِرَ الْعَهْدِ مِنّي اِلَيْكُما، | ទូលព្រះបង្គំសូមគោរពលាព្រះអង្គទាំងពីរ(عليهم السلام)ដោយផ្ញើខ្លួនលើអល់ឡោះហ៍(عزوجل) សូមអល់ឡោះហ៍(عزوجل)កុំធ្វើឲ្យលើកនេះជាលើកចុងក្រោយបង្អស់ដែលទូលព្រះបង្គំស៊ីរ៉ាស់ព្រះអង្គទាំងពីរ(عليهم السلام) ។ |
| اِنْصَرَفْتُ يا سَيِّدِي يا اَمِيرَ الْمُؤْمِنِينَ وَمَوْلَايَ وَاَنْتَ يا | ទូលព្រះបង្គំសូមគោរពលាហើយ ឱព្រះអគ្គនាយកទូលព្រះបង្គំ អាមីរុល-មុមីនីន(صلوات الله عليه والسلام)អើយ និងព្រះអង្គ(صلوات الله عليه والسلام) អាប៊ូ |

وَالْوَسِيلَةَ ،

កិត្តិយសប្រសើរ មានឋានន្តរសក្តិឧត្តម ហើយជាទីទុកចិត្ត[របស់អល់ឡោះហ្ម៍ عز وجل]

إِنِّي أَنْقَلِبُ عَنْكُما مُنْتَظِرًا لِتَنجُزِ الْحاجَةِ وَقَضائِها وَنَجاحِها مِنَ اللهِ بِشَفاعَتِكُما لِي إِلَى اللهِ فِي ذَلِكَ ،

ទូលព្រះបង្គំដកខ្លួនចេញពីព្រះអង្គទាំងពីរ عليهم السلام ត្រឡប់វិញ ដោយរង់ចាំអល់ឡោះហ្ម៍ عز وجل ធ្វើឲ្យសំណូមពរទូលព្រះបង្គំបានសម្រេចដូចប្រាថ្នា សក្តិសមតាមបំណងនិងបានជោគជ័យដោយសារព្រះអង្គទាំងពីរ عليهم السلام ជួយធ្វើអន្តរាគមន៍ចំពោះអល់ឡោះហ្ម៍ عز وجل ឲ្យទូលព្រះបង្គំ ។

فَلا أَخِيبُ وَلا يَكُونُ مُنْقَلَبِي مُنْقَلَبًا خائِبًا خاسِرًا

សូមកុំឲ្យទូលព្រះបង្គំខូចចិត្ត សូមកុំឲ្យទូលព្រះបង្គំត្រឡប់វិញជាបុគ្គលខូចចិត្តជាបុគ្គលបរាជ័យឡើយ

بَلْ يَكُونُ مُنْقَلَبِي مُنْقَلَبًا راجِحًا مُفْلِحًا مُنْجِحًا مُسْتَجابًا بِقَضاءِ جَمِيعِ حَوائِجِي، وَتَشَفَّعا لِي إِلَى اللهِ.

តែសូមឲ្យទូលព្រះបង្គំត្រឡប់វិញដោយមានសង្ឃឹម ដោយសេចក្តីសម្រេច ដោយជោគជ័យ ដោយបានសម្រេចតាមបំណងគ្រប់សំណូមពរ ។ សូមព្រះអង្គទាំងពី عليهم السلام ជួយធ្វើអន្តរាគមន៍ចំពោះអល់ឡោះហ្ម៍ عز وجل ឲ្យទូលព្រះបង្គំផង ។

إِنْقَلَبْتُ عَلَى ماشاءَ اللهُ وَلا حَوْلَ وَلا قُوَّةَ إِلَّا بِاللهِ مُفَوِّضًا أَمْرِي إِلَى اللهِ

ទូលព្រះបង្គំត្រឡប់វិញជាមួយអ្វីដែលអល់ឡោះហ្ម៍ عز وجل មានព្រះបំណង ពុំមានកម្លាំងនិងឥទ្ធិពលក្រៅពីអាស្រ័យលើអល់ឡោះហ្ម៍ عز وجل ឡើយ ដោយទុកកាយ



ثارِهِ وَالْوِتْرَ الْمَوْتُورَ ،

ឱបុគ្គលអ្នកសងសឹករបស់អល់ឡោះហ្ម៍ ឱព្រះរាជបុត្ររបស់បុគ្គលអ្នកសងសឹករបស់អល់ឡោះហ្ម៍ ឱអ្នកសងសឹក អ្នកទាមទារការសងសឹក

السَّلامُ عَلَيْكَ وَعَلى الأَرْواحِ الَّتِي حَلَّتْ بِفِنائِكَ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ صلوات الله عليه والسلام និងកើតមានដល់វិញ្ញាណទាំងឡាយដែលនៅលើទីធ្លាព្រះអង្គ

عَلَيْكُمْ مِنِّي جَمِيعًا سَلامُ اللهِ أَبَدًا مابَقِيتُ وَبَقِيَ اللَّيْلُ وَالنَّهارُ

សូមអល់ឡោះហ្ម៍ عز وجل ប្រសិទ្ធិពរជ័យដល់អ្នកទាំងអស់គ្នា ពីខ្ញុំ រហូតតរៀងទៅ ដរាបណាខ្ញុំនៅមានជីវិត ដរាបណានៅតែមានយប់និងថ្ងៃ

يا أَبا عَبْدِ اللهِ لَقَدْ عَظُمَتِ الرَّزِيَّةُ وَجَلَّتْ وَعَظُمَتِ الْمُصِيبَةُ بِكَ عَلَيْنا وَعَلى جَمِيعِ أَهْلِ الْإِسْلامِ ،

អាប៊ូ អាប់ឌុលឡោះហ្ម៍ صلوات الله عليه والسلام អឺយ បាត់បង់ព្រះអង្គ صلوات الله عليه والسلام ជាអកុសលធំបំផុត មហន្តរាយនេះគួរឲ្យខ្លាចណាស់ ពិបាកអត់ទ្រាំណាស់សម្រាប់អស់ទូលបង្គំនិងសម្រាប់អ៊ីស្លាមសាសនិកជនទាំងអស់

وَجَلَّتْ وَعَظُمَتْ مُصِيبَتُكَ فِي السَّماواتِ عَلى جَمِيعِ أَهْلِ السَّماواتِ ،

បាត់បង់ព្រះអង្គ صلوات الله عليه والسلام ជាអកុសលធំបំផុត មហន្តរាយនេះគួរឲ្យខ្លាចណាស់ ពិបាកអត់ទ្រាំណាស់នៅលើមេឃផងដែរសម្រាប់ប្រជានិករមេឃទាំងអស់

فَلَعَنَ اللهُ أُمَّةً أَسَّسَتْ أَساسَ

សូមអល់ឡោះហ្ម៍ عز وجل ដាក់បណ្តាសាប្រជា

الظُّلْمِ وَالْجَوْرِ عَلَيْكُمْ أَهْلَ الْبَيْتِ ،

និករដែលចាក់គ្រឹះអយុត្តិធម៌ ដែលព្យាយាមធ្វើបាបព្រះអង្គទាំងឡាយ ឱព្រះរាជកុលដ្ឋានអើយ عليهم السلام

وَلَعَنَ اللهُ أُمَّةً دَفَعَتْكُمْ عَنْ مَقامِكُمْ وَأَزالَتْكُمْ عَنْ مَراتِبِكُمُ الَّتِي رَتَّبَكُمُ اللهُ فِيها ،

សូមអល់ឡោះហ៍ عزّ وجلّ ដាក់បណ្ដាសាប្រជានិករដែលបំបាត់ឋានៈព្រះអង្គ عليهم السلام ដែលប្លន់យកបុណ្យស័ក្តិព្រះអង្គ عليهم السلام ដែលអល់ឡោះហ៍ عزّ وجلّ បានព្រះរាជទានឲ្យព្រះអង្គ عليهم السلام ជាច់មុខ

وَلَعَنَ اللهُ أُمَّةً قَتَلَتْكُمْ وَلَعَنَ اللهُ الْمُمَهِّدِينَ لَهُمْ بِالتَّمْكِينِ مِنْ قِتالِكُمْ ،

សូមអល់ឡោះហ៍ عزّ وجلّ ដាក់បណ្ដាសាប្រជានិករដែលបានសម្លាប់ព្រះអង្គ عليهم السلام សូមអល់ឡោះហ៍ عزّ وجلّ ដាក់បណ្ដាសាពួករួមដៃដើម្បីកម្ចាត់ព្រះអង្គ عليهم السلام បានសម្រេច

بَرِئْتُ إِلى اللهِ وَإِلَيْكُمْ مِنْهُمْ وَمِنْ أَشْياعِهِمْ وَأَتْباعِهِمْ وَأَوْلِيائِهِمْ.

ទូលព្រះបង្គំសូមប្រកាស ចំពោះមុខអល់ឡោះហ៍ عزّ وجلّ និងចំពោះមុខព្រះអង្គ عليهم السلام ទាំងឡាយថាខ្ញុំទូលព្រះបង្គំបដិសេធពួកគេ បក្សពួកពួកគេ ពួកគាំទ្រពួកគេនិងបណ្ដាមិត្តពួកគេ

يا أَبا عَبْدِ اللَّهِ إِنِّي سِلْمٌ لِمَنْ سالَمَكُمْ وَحَرْبٌ لِمَنْ حارَبَكُمْ إِلَى يَوْمِ الْقِيامَةِ ،

អាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام អើយ ទូលព្រះបង្គំស្រុះស្រួលជាមួយបុគ្គលណាដែលស្រុះស្រួលជាមួយព្រះអង្គ عليهم السلام ទូលព្រះបង្គំប្រយុទ្ធតទល់បុគ្គលណាដែលប្រយុទ្ធតទល់ព្រះអង្គ عليهم السلام ទូលបង្គំ



تُفَرِّقْ بَيْنِي وَبَيْنَهُمْ طَرْفَةَ عَيْنٍ أَبَدًا فِي الدُّنْيا وَالآخِرَةِ

ទាំងនេះ عليهم السلام បានចូលទិវង្គតដែរ ។ សូមព្រះអង្គ عزّ وجلّ ឲ្យទូលព្រះបង្គំជាខ្ញុំបានទទួលអនិច្ចកម្មជាអ្នកអនុវត្តិតាមសាសនាព្រះអង្គទាំងនេះ عليهم السلام សូមព្រះអង្គ عزّ وجلّ ឲ្យទូលព្រះបង្គំជាខ្ញុំបានរស់ឡើងវិញនៅក្នុងក្រុមព្រះអង្គទាំងនេះ عليهم السلام សូមព្រះអង្គ عزّ وجلّ កុំបំបែកទូលព្រះបង្គំជាខ្ញុំពីព្រះអង្គទាំងនេះ عليهم السلام សូម្បីតែមួយប៉ប្រិចភ្នែកឡើយ ទាំងក្នុងលោកនេះនិងក្នុងលោកមុខ

يا أَمِيرَ الْمُؤْمِنِينَ وَيا أَبا عَبْدِ اللهِ أَتَيْتُكُما زائِرًا وَمُتَوَسِّلًا إِلَى اللهِ رَبِّي وَرَبِّكُما وَمُتَوَجِّهًا إِلَيْهِ بِكُما وَمُسْتَشْفِعًا بِكُما إِلَى اللهِ تَعالَى فِي حاجَتِي هٰذِهِ

អាមីរុល-មុមីនីន صلوات الله عليه والسلام អាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام អើយ ទូលព្រះបង្គំមករកព្រះអង្គទាំងពីរ عليهم السلام ស៊ីរ៉ាស់ព្រះអង្គ عليهم السلام ដោយបួងសួងអល់ឡោះហ៍ عزّ وجلّ ព្រះម្ចាស់ عزّ وجلّ ទូលព្រះបង្គំ ព្រះម្ចាស់ عزّ وجلّ របស់ព្រះអង្គទាំងពីរ عليهم السلام ដោយបែរទៅរកព្រះអង្គ عزّ وجلّ តាមរយៈព្រះអង្គទាំងពីរ عليهم السلام សូមឲ្យព្រះអង្គទាំងពីរជួយធ្វើអន្តរាគមន៍ចំពោះអល់ឡោះហ៍ عزّ وجلّ ឲ្យទូលព្រះបង្គំដែលមានសំណូមពរទាំងនេះនោះ ។

فاشْفَعا لِي فَإِنَّ لَكُما عِنْدَ اللهِ الْمَقامَ الْمَحْمُودَ وَالْجاهَ الْوَجِيهَ وَالْمَنْزِلَ الرَّفِيعَ

ដូច្នេះ សូមព្រះអង្គទាំងពីរ عليهم السلام ជួយធ្វើអន្តរាគមន៍ឲ្យទូលព្រះបង្គំផង ពីព្រោះព្រះអង្គទាំងពីរ عليهم السلام មានបុណ្យស័ក្តិជាទីសរសើរសម្រាប់អល់ឡោះហ៍ عزّ وجلّ មានព្រះ

ដោយកុំឲ្យវាធ្វើឲ្យទូលព្រះបង្គំជាខ្ញុំសៅហ្មង

وَاصْرِفْنِي بِقَضاءِ حَوائِجِي وَكِفايَةِ ما أَهَمَّنِي هَمُّهُ مِنْ أَمْرِ آخِرَتِي وَدُنْيايَ.

សូមព្រះអង្គ عزوجل ឲ្យទូលព្រះបង្គំជាខ្ញុំចាកចេញពីទីនេះដោយបានសម្រេចដូចបំណង និងទទួលបាននូវដំណោះស្រាយបញ្ហាដែលធ្វើទូលព្រះបង្គំជាខ្ញុំបារម្ភរឿងលោកមុខនិងរឿងលោកនេះ

يا أَمِيرَ الْمُؤْمِنينَ وَيا أَبا عَبْدِ اللهِ عَلَيْكُما مِنِّي سَلامُ اللهِ أَبَدًا ما بَقِيتُ وَ بَقِيَ اللَّيْلُ وَالنَّهارُ

អាមីរុល-មុមីនីន صلوات الله عليه والسلام អាប៊ូអាប់ឌុលឡោះហ្ស៍ صلوات الله عليه والسلام អឺយ សូមសិរីសួស្តីអល់ឡោះហ្ស៍ عزوجل កើតមានដល់ព្រះអង្គទាំងពីរ عليهم السلام ពីទូលព្រះបង្គំ រហូតតរៀងទៅដរាបណានៅតែមានយប់និងថ្ងៃ

وَ لا جَعَلَهُ اللهُ آخِرَ الْعَهْدِ مِنْ زِيارَتِكُما وَلا فَرَّقَ اللهُ بَيْنِي وَبَيْنَكُما ،

សូមអល់ឡោះហ្ស៍ عزوجل កុំឲ្យលើកនេះជាលើកចុងក្រោយបង្អស់ដែលទូលបង្គំស៊ីរ៉ាស់ព្រះអង្គទាំងពីរ عليهم السلام សូមកុំឲ្យអល់ឡោះហ្ស៍ عزوجل បំបែកទូលព្រះបង្គំពីព្រះអង្គទាំងពីរ عليهم السلام ។

اللّٰهُمَّ أَحْيِنِي حَياةَ مُحَمَّدٍ وَذُرِّيَّتِهِ وَأَمِتْنِي مَماتَهُمْ وَتَوَفَّنِي عَلَى مِلَّتِهِمْ وَاحْشُرْنِي فِي زُمْرَتِهِمْ وَلا

អល់ឡោះហ្ស៍ عزوجل អឺយ សូមព្រះអង្គ عزوجل ឲ្យទូលព្រះបង្គំជាខ្ញុំបានរស់នៅដូចមូហាំម៉ាដ់ صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ់ صلى الله عليه وآله وسلم បានរស់នៅដែរនោះ សូមព្រះអង្គ عزوجل ឲ្យទូលព្រះបង្គំជាខ្ញុំបានស្លាប់ដូចព្រះអង្គ



ជាមិត្តរបស់បុគ្គលណាដែលជាមិត្តរបស់ព្រះអង្គ عليهم السلام ជាសត្រូវរបស់បុគ្គលណាដែលប្រឆាំងព្រះអង្គ عليهم السلام រហូតដល់ថ្ងៃរស់ឡើងវិញ

وَلَعَنَ اللهُ آلَ زِيادٍ وَآلَ مَرْوانٍ وَلَعَنَ اللهُ بَنِي أُمَيَّةَ قاطِبَةً وَلَعَنَ اللهُ ابْنَ مَرْجانَةَ وَلَعَنَ اللهُ عُمَرَ بْنَ سَعْدٍ وَلَعَنَ اللهُ شِمْرًا ،

សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសាត្រកូលស៊ីយ៉ាដ់និងត្រកូលម៉ារវ៉ាន សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសា បានីអ៊ូម៉ៃយ៉ាស់ដោយឥតរើសមុខ សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសា បានីម៉ារយ៉ាណាស់ សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសាអ៊ុម៉ារ ប៊ិន សាក់ដ៏ សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសាស៊ីមរ៍

وَلَعَنَ اللهُ أُمَّةً أَسْرَجَتْ وَأَلْجَمَتْ وَتَنَقَّبَتْ لِقِتالِكَ ،

សូមអល់ឡោះហ្ស៍ عزوجل ដាក់បណ្តាសាប្រជានិករដែលបានជិះលើអានសេះ ដែលបានចងបង្ហៀរសេះ ដែលបានប្រុងខ្លួនប្រយុទ្ធតទល់ព្រះអង្គ صلوات الله عليه والسلام

بِأَبِي أَنْتَ وَأُمِّي لَقَدْ عَظُمَ مُصابِي بِكَ

ទូលព្រះបង្គំសូមបូជាឪពុកម្តាយដើម្បីព្រះអង្គ صلوات الله عليه والسلام ទុក្ខសោកទូលបង្គំ[ដែលបានបាត់បង់ព្រះអង្គ صلوات الله عليه والسلام នោះ]ធំណាស់

فَأَسْأَلُ اللهَ الَّذِي أَكْرَمَ مَقامَكَ

ទូលព្រះបង្គំសូមអល់ឡោះហ្ស៍ عزوجل ដែលបានផ្តល់កិត្តិយសដល់ព្រះអង្គ صلوات الله عليه والسلام

وَأَكْرَمَني بِكَ، أَنْ يَرْزُقَني طَلَبَ ثارِكَ مَعَ إِمامٍ مَنْصُورٍ مِنْ أَهْلِ بَيْتِ مُحَمَّدٍ صَلَّى اللهُ عَلَيهِ وَآلِهِ.

ដោយបុណ្យស័ក្តិ ហើយដែលបានផ្តល់កិត្តិយសដល់ទូលព្រះបង្គំដោយរូបព្រះអង្គ(صلوات الله عليه والسلام) ឲ្យទូលបង្គំបានសងសឹកឲ្យព្រះអង្គ(صلوات الله عليه والسلام)ជុំជាមួយអ៊ីម៉ាំជោគជ័យដែលជាព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ្ឋ(صلى الله عليه وآله وسلم)

اَللَّهُمَّ اجْعَلْني عِنْدَكَ وَجيهًا بِالْحُسَيْنِ عَلَيْهِ السَّلامُ فِي الدُّنْيا وَالْأخِرَةِ،

អល់ឡោះហ្វ៎(عزوجل)អឺយ សូមឲ្យទូលព្រះបង្គំគាប់ព្រះហឫទ័យព្រះអង្គ(عزوجل) ដោយសារអាល់-ហ៊្វូសែន៍(صلوات الله عليه والسلام) ក្នុងលោកនេះនិងលោកមុខ

يا أَبا عَبْدِ اللهِ إِنِّي أَتَقَرَّبُ إِلَى اللهِ وَإِلَى رَسُولِهِ وَإِلَى أَمِيرِ الْمُؤْمِنِينَ وَإِلَى فاطِمَةَ وَإِلَى الْحَسَنِ وَإِلَيْكَ بِمُوالاتِكَ

អាប៊ូ អាប់ឌុលឡោះហ្វ៎(صلوات الله عليه والسلام)អឺយ ទូលព្រះបង្គំចូលទៅជិតអល់ឡោះហ្វ៎(عزوجل) ជិតព្រះសាសនៈទូត(صلى الله عليه وآله وسلم)ព្រះអង្គ(عزوجل) ជិតព្រះរាជអគ្គមហាប្រមុខ(صلوات الله عليه والسلام)របស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា ជិតហ្វាទីម៉ាស់(سلام الله عليها) ជិតអាល់-ហាសាន់(صلوات الله عليه والسلام) និងជិតព្រះអង្គ(صلوات الله عليه والسلام) ដោយសារទូលបង្គំស្រឡាញ់ (គឺតាម) ព្រះអង្គ(صلوات الله عليه والسلام) ។

وَبِالْبَرائَةِ مِمَّنْ قاتَلَكَ وَنَصَبَ لَكَ الْحَرْبَ وَبِالْبَرائَةِ مِمَّنْ أَسَّسَ أَساسَ الظُّلْمِ وَالْجَوْرِ

ដោយសារទូលព្រះបង្គំប្រានចោលអស់បុគ្គលដែលប្រឆាំងនិងប្រយុទ្ធតទល់ព្រះអង្គ(صلوات الله عليه والسلام) និងដោយសារទូលព្រះបង្គំប្រានចោលអស់បុគ្គលដែលចាក់



وَأَنْ تَكْشِفَ عَنِّي غَمِّي وَهَمِّي وَكَرْبِي فِي مَقامِي هَذا كَما كَشَفْتَ عَنْ نَبِيِّكَ هَمَّهُ وَغَمَّهُ وَكَرْبَهُ وَكَفَيْتَهُ هَوْلَ عَدُوِّهِ ،

[សូម]ឲ្យកម្ចាត់សេចក្តីសៅហ្មង សេចក្តីបារម្ភនិងទុក្ខព្រួយពីទូលព្រះបង្គំជាខ្ញុំនាទីនេះ ដូចព្រះអង្គ(عزوجل)បានកម្ចាត់សេចក្តីសៅហ្មង សេចក្តីបារម្ភនិងទុក្ខព្រួយពីព្រះសាស្តា(صلى الله عليه وآله وسلم)ព្រះអង្គ(عزوجل) ហើយព្រះអង្គ(عزوجل)បានថែរក្សាព្រះអង្គ(صلى الله عليه وآله وسلم)ឲ្យផុតពីការភ័យខ្លាចសត្រូវព្រះអង្គ(صلى الله عليه وآله وسلم)ដែរ

فَاكْشِفْ عَنِّي كَما كَشَفْتَ عَنْهُ وَفَرِّجْ عَنِّي كَما فَرَّجْتَ عَنْهُ وَاكْفِنِي كَما كَفَيْتَهُ

ដូច្នេះសូមព្រះអង្គ(عزوجل)បំបាត់ពីទូលព្រះបង្គំជាខ្ញុំនូវអ្វីដែលព្រះអង្គ(عزوجل)បានបំបាត់ពីព្រះសាស្តា(صلى الله عليه وآله وسلم)ដែរ សូមព្រះអង្គ(عزوجل)ឲ្យទូលព្រះបង្គំជាខ្ញុំបានធូរស្រាលដូចព្រះអង្គ(عزوجل)បានធ្វើឲ្យព្រះសាស្តា(صلى الله عليه وآله وسلم)បានធូរស្រាលដែរ សូមព្រះអង្គ(عزوجل)ថែរក្សាទូលព្រះបង្គំជាខ្ញុំដូចព្រះអង្គ(عزوجل)បានថែរក្សាព្រះសាស្តា(صلى الله عليه وآله وسلم)ដែរ

وَاصْرِفْ عَنِّي هَوْلَ ما أَخافُ هَوْلَهُ وَمَؤُونَةَ ما أَخافُ مَؤُونَتَهُ وَهَمَّ ما أَخافُ هَمَّهُ بِلا مَؤُونَةٍ عَلَى نَفْسِى مِنْ ذَلِكَ ،

សូមព្រះអង្គ(عزوجل)ប្រានឆ្ងាយពីទូលព្រះបង្គំជាខ្ញុំនូវគ្រោះថ្នាក់របស់អ្វីដែលប្រកបដោយគ្រោះថ្នាក់ ដែលទូលព្រះបង្គំជាខ្ញុំខ្លាច [សូមព្រះអង្គ(عزوجل)ប្រានឆ្ងាយពីទូលព្រះបង្គំជាខ្ញុំនូវ] បន្ទុកធ្ងន់របស់អ្វីដែលមានបន្ទុកធ្ងន់ដែលទូលព្រះបង្គំជាខ្ញុំខ្លាច និងសេចក្តីបារម្ភរបស់អ្វីដែលប្រកបដោយសេចក្តីបារម្ភដែលទូលព្រះបង្គំជាខ្ញុំខ្លាច

فَبِكَ أَسْتَفْتِحُ وَبِكَ أَسْتَنْجِحُ وَبِمُحَمَّدٍ وَآلِ مُحَمَّدٍ أَتَوَجَّهُ إِلَيْكَ وَأَتَوَسَّلُ وَأَتَشَفَّعُ ،

ទូលព្រះបង្គំជាខ្ញុំចាប់ផ្ដើមតាមរយៈព្រះអង្គ(عزّ وجلّ) ទូលព្រះបង្គំជាខ្ញុំស្វែងរកជោគជ័យតាមរយៈព្រះអង្គ(عزّ وجلّ)។ ទូលព្រះបង្គំជាខ្ញុំសំដៅទៅរកព្រះអង្គ(عزّ وجلّ)តាមរយៈមូហ្ហាំម៉ាដ់(ﷺ)និងព្រះរាជកុលដ្ឋាន(عليهم السلام)របស់មូហ្ហាំម៉ាដ់(ﷺ)។ ទូលព្រះបង្គំជាខ្ញុំបួងសួងព្រះអង្គ(عزّ وجلّ)តាមរយៈវរបុគ្គទាំង(عليهم السلام)នេះ ទូលព្រះបង្គំជាខ្ញុំសូមឲ្យវរបុគ្គលទាំងនេះ(عليهم السلام)ជួយធ្វើអន្តរាគមន៍ចំពោះព្រះអង្គ(عزّ وجلّ)។

فَأَسْأَلُكَ يا اللهُ يا اللهُ يا اللهُ فَلَكَ الْحَمْدُ وَلَكَ الشُّكْرُ وَإِلَيْكَ الْمُشْتَكى وَأَنْتَ الْمُسْتَعانُ ،

ដូច្នេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គ(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) សូមថ្វាយបសំសាចំពោះព្រះអង្គ(عزّ وجلّ) សូមថ្វាយព្រះអំណរគុណចំពោះព្រះអង្គ(عزّ وجلّ) គេប្ដឹងផ្ដល់តវ៉ាចំពោះព្រះអង្គ(عزّ وجلّ) គេសូមជំនួយពីព្រះអង្គ(عزّ وجلّ)។

فَأَسْأَلُكَ يا اللهُ يا اللهُ يا اللهُ بِحَقِّ مُحَمَّدٍ وَآلِ مُحَمَّدٍ أَنْ تُصَلِّيَ عَلَى مُحَمَّدٍ وَآلِ مُحَمَّدٍ

ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គ(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) ឱអល់ឡោះហ៍(عزّ وجلّ) ក្នុងនាមនៃព្រះរាជសិទ្ធិរបស់មូហ្ហាំម៉ាដ់(ﷺ)និងព្រះរាជកុលដ្ឋាន(عليهم السلام)របស់មូហ្ហាំម៉ាដ់(ﷺ) ឲ្យព្រះអង្គ(عزّ وجلّ)ប្រសិទ្ធពរជ័យ ដល់មូហ្ហាំម៉ាដ់(ﷺ)និងដល់ព្រះរាជកុលដ្ឋាន(عليهم السلام)របស់មូហ្ហាំម៉ាដ់(ﷺ)



عَلَيْكُمْ ،

គ្រឹះអយុត្តិធម៌ ដែលព្យាយាមធ្វើបាបព្រះអង្គទាំងឡាយ(عليهم السلام)

وَأَبْرَأُ إِلَى اللهِ وَإِلَى رَسُولِهِ مِمَّنْ أَسَّسَ أَساسَ ذلِكَ وَبَنى عَلَيهِ بُنْيانَهُ وَجَرى فِي ظُلْمِهِ وَجَوْرِهِ عَلَيْكُمْ وَعَلى أَشْياعِكُمْ

ទូលព្រះបង្គំសូមប្រកាស ចំពោះមុខអល់ឡោះហ៍(عزّ وجلّ)និងចំពោះមុខព្រះសាសនៈទូតព្រះអង្គ(ﷺ) ថាទូលព្រះបង្គំមិនជាប់ទាក់ទងនឹងអស់បុគ្គលដែលបានចាក់គ្រឹះនេះ (គឺបង្កសោកនាដកម្មព្រះអង្គ(عليهم السلام)) ដែលតាំងមូលដ្ឋាននៅលើនោះ ដែលបន្តការសង្កត់សង្កិននិងអំពើអយុត្តិធម៌មកលើព្រះអង្គ(عليهم السلام)និងកនព្រះអង្គ(عليهم السلام)នោះទេ

بَرِئْتُ إِلَى اللهِ وَإِلَيْكُمْ مِنْهُمْ وَأَتَقَرَّبُ إِلَى اللهِ ثُمَّ إِلَيْكُمْ بِمُوالاتِكُمْ وَمُوالاةِ وَلِيِّكُمْ

ទូលព្រះបង្គំសូមច្រានចោលពួកនោះនៅចំពោះមុខអល់ឡោះហ៍(عزّ وجلّ)និងចំពោះមុខព្រះអង្គ(عليهم السلام) ហើយទូលព្រះបង្គំចូលជិតអល់ឡោះហ៍(عزّ وجلّ)និងជិតព្រះអង្គ(عليهم السلام) អាស្រ័យសេចក្ដីស្រឡាញ់ (គឺអាស្រ័យការគោរព) ព្រះអង្គ(عليهم السلام)និងអាស្រ័យសេចក្ដីស្រឡាញ់បុគ្គលដែលព្រះអង្គ(عليهم السلام)ស្រឡាញ់

وَبِالْبَراءَةِ مِنْ اَعْدائِكُمْ وَالنّاصِبِينَ لَكُمُ الْحَرْبَ

អាស្រ័យការច្រានចោលពួកសត្រូវរបស់ព្រះអង្គ(عليهم السلام)និងពួកដែលប្រយុទ្ធតទល់ព្រះអង្គ(عليهم السلام) និងអាស្រ័យការបដិសេធ

وَبِالْبَراءَةِ مِنْ اَشْياعِهِمْ وَاَتْباعِهِمْ،

បក្សពួករបស់ពួកគេនិងពួកដែលតាមពួកគេទាំងនោះ

إِنِّي سِلْمٌ لِمَنْ سالَمَكُمْ وَحَرْبٌ لِمَنْ حارَبَكُمْ وَوَلِيٌّ لِمَنْ والاكُمْ وَعَدُوٌّ لِمَنْ عاداكُمْ ،

ទូលព្រះបង្គំស្រុះស្រួលជាមួយអស់បុគ្គលដែលស្រុះស្រួលជាមួយព្រះអង្គ عليهم السلام ទូលបង្គំព្រះប្រយុទ្ធតទល់អស់បុគ្គលដែលប្រយុទ្ធតទល់ព្រះអង្គ عليهم السلام ទូលព្រះបង្គំជាមិត្តរបស់អស់បុគ្គលដែលជាមិត្តរបស់ព្រះអង្គ عليهم السلام ទូលព្រះបង្គំជាសត្រូវរបស់អស់បុគ្គលដែលជាសត្រូវរបស់ព្រះអង្គ عليهم السلام

فَأَسْأَلُ اللهَ الَّذِي أَكْرَمَنِي بِمَعْرِفَتِكُمْ وَمَعْرِفَةِ أَوْلِيائِكُمْ وَرَزَقَنِي الْبَرائَةِ مِنْ أَعْدائِكُمْ أَنْ يَجْعَلَنِي مَعَكُمْ فِي الدُّنْيا وَالآخِرَةِ وَأَنْ يُثَبِّتَ لِي عِنْدَكُمْ قَدَمَ صِدْقٍ فِي الدُّنْيا وَالآخِرَةِ ،

ទូលព្រះបង្គំសូមអល់ឡោះហ៊្ 	عز وجل ដែលបានឲ្យទូលបង្គំបានស្គាល់ព្រះអង្គ عليهم السلام ជាកិត្តិយស់ ដែលបានឲ្យទូលបង្គំស្គាល់កនព្រះអង្គ عليهم السلام និងដែលបានឲ្យទូលព្រះបង្គំមិនជាប់ទាក់ទងនឹងពួកសត្រូវរបស់ព្រះអង្គ عليهم السلام ឲ្យទូលបង្គំបាននៅក្បែរព្រះអង្គ عليهم السلام ក្នុងលោកនេះនិងក្នុងលោកមុខ ហើយសូមអល់ឡោះហ៊្ عز وجل ឲ្យទូលព្រះបង្គំមានសេចក្តីស្មោះត្រង់ចំពោះព្រះអង្គ عليهم السلام កាន់តែមាំឡើងក្នុងលោកនេះ និងក្នុងលោកមុខ



لا كافِيَ سِواكَ

ពុំមានអ្នកណាអាចជួយការពារឲ្យរួចផុតបានឡើយ ព្រោះព្រះអង្គ عز وجل ជាអ្នកការពារ ពុំមានអ្នកការពារក្រៅពីព្រះអង្គ عز وجل ឡើយ

وَمُفَرِّجٌ لا مُفَرِّجَ سِواكَ وَمُغِيثٌ لا مُغِيثَ سِواكَ وَجارٌ لا جارَ سِواكَ ؛

ព្រះអង្គ عز وجل ជាអ្នករំដោះ ពុំមានអ្នករំដោះក្រៅពីព្រះអង្គ عز وجل ទេ ព្រះអង្គ عز وجل ជាអ្នកសង្គ្រោះ ពុំអ្នកសង្គ្រោះក្រៅពីព្រះអង្គ عز وجل ទេ ព្រះអង្គ عز وجل អ្នកឲ្យជម្រក ពុំអ្នកឲ្យជម្រកក្រៅពីព្រះអង្គ عز وجل ទេ

خابَ مَنْ كانَ جارُهُ سِواكَ وَمُغِيثُهُ سِواكَ وَمَفْزَعُهُ إِلَى سِواكَ وَمَهْرَبُهُ إِلَى سِواكَ وَمَلْجَأُهُ إِلَى غَيْرِكَ وَمَنْجاهُ مِنْ مَخْلُوقٍ غَيْرِكَ.

បរាជ័យគឺបុគ្គលដែលយកអ្នកជួយទំនុកបម្រុងក្រៅពីព្រះអង្គ عز وجل ដែលសូមជំនួយពីអ្នកផ្សេងពីព្រះអង្គ عز وجل ដែលមានជម្រកក្រៅពីព្រះអង្គ عز وجل ដែលមានទីជ្រកកោនក្រៅពីទីជ្រកកោនរបស់ព្រះអង្គ عز وجل ដែលស្នាក់នៅជាមួយអ្នកផ្សេងពីព្រះអង្គ عز وجل ដែលមានអ្នកសង្គ្រោះជាសត្វលោករបស់ព្រះអង្គ عز وجل ក្រៅពីព្រះអង្គ عز وجل ។

فَأَنْتَ ثِقَتِي وَرَجائِي وَمَفْزَعِي وَمَهْرَبِي وَمَلْجَأِي وَمَنْجايَ

ពីព្រោះព្រះអង្គ عز وجل ជាសេចក្តីទុកចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ ជាសេចក្តីសង្ឃឹមរបស់ទូលព្រះបង្គំជាខ្ញុំ ជាជម្រករបស់ទូលព្រះបង្គំជាខ្ញុំ ជាទីជ្រកកោនរបស់ទូលព្រះបង្គំជាខ្ញុំ ជាទីសំណាក់របស់ទូលព្រះបង្គំជាខ្ញុំ ជាអ្នកសង្គ្រោះទូលព្រះបង្គំជាខ្ញុំ

عَيْنَيْهِ وَأَدْخِلْ عَلَيْهِ الْفَقْرَ فِي مَنْزِلِهِ وَالْعِلَّةَ وَالسَّقْمَ فِي بَدَنِهِ

បុគ្គលនោះស្គាល់សេចក្ដីអាប់ឱនដោយផ្ទាល់ ឲ្យភាពក្រីក្រចូលដល់ក្នុងលំនៅអ្នកនោះ ឲ្យទុព្វលភាពនិងជម្ងឺចូលទៅក្នុងខ្លួនបុគ្គលនោះ

حَتّى تَشْغَلَهُ عَنِّي بِشُغْلٍ شاغِلٍ لا فَراغَ لَهُ ، وَأَنْسِهِ ذِكْرِي كَما أَنْسَيْتَهُ ذِكْرَكَ

ដើម្បីធ្វើឲ្យបុគ្គលនោះរវល់ហើយបែរចេញឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ ដោយការរវល់ដោះដៃមិនរួច មិនឲ្យសម្រាកបាន សូមព្រះអង្គعزوجلធ្វើឲ្យបុគ្គលនោះភ្លេចនឹកនាដល់ទូលព្រះបង្គំជាខ្ញុំ ដូចព្រះអង្គعزوجلធ្វើឲ្យបុគ្គលនោះភ្លេចនឹកនាដល់ព្រះអង្គعزوجلនោះដែរ

وَخُذْ عَنِّي بِسَمْعِهِ وَبَصَرِهِ وَلِسانِهِ وَيَدِهِ وَرِجْلِهِ وَقَلْبِهِ وَجَمِيعِ جَوارِحِهِ ،

សូមព្រះអង្គعزوجلធ្វើឲ្យត្រចៀក ភ្នែក អណ្ដាត ដៃ ជើង បេះដូងនិងសរីរាង្គទាំងឡាយរបស់បុគ្គលនោះឃ្លាតឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ

وَأَدْخِلْ عَلَيْهِ فِي جَمِيعِ ذَلِكَ السُّقْمَ وَلَا تُشْفِهِ حَتّى تَجْعَلَ ذَلِكَ لَهُ شُغْلًا شاغِلًا بِهِ عَنِّي وَعَنْ ذِكْرِي

សូមព្រះអង្គعزوجلធ្វើឲ្យជម្ងឺចូលទៅក្នុងខ្លួនបុគ្គលទាំងនោះរាល់គ្នា កុំធ្វើឲ្យជាសះស្បើយ បណ្ដាលឲ្យបុគ្គលរាល់គ្នានោះរវល់តែនឹងជម្ងឺនោះ ឃ្លាតឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ មិននឹកនាដល់ទូលព្រះបង្គំជាខ្ញុំ

وَاكْفِنِي يا كافِيَ ما لا يَكْفِي سِواكَ فَإِنَّكَ الْكافِي

សូមព្រះអង្គعزوجلជួយការពារទូលព្រះបង្គំជាខ្ញុំ ឱព្រះអ្នកជួយការពារឲ្យរួចផុតពីអ្វីដែល



وَأَسْأَلُهُ أَنْ يُبَلِّغَنِي الْمَقامَ الْمَحْمُودَ لَكُمْ عِنْدَ اللهِ وَأَنْ يَرْزُقَنِي طَلَبَ ثارِي مَعَ إِمامٍ هُدًى ظاهِرٍ ناطِقٍ بِالْحَقِّ مِنْكُمْ ،

ទូលព្រះបង្គំសូមឲ្យអល់ឡោះហ៍عزوجلឲ្យទូលបង្គំបានទៅដល់លំដាប់ថ្នាក់ជាទីកោតសរសើរដែលអល់ឡោះហ៍عزوجلបានប្រទានឲ្យព្រះអង្គعليهم السلامនោះ ហើយទូលព្រះបង្គំសូមព្រះអង្គعزوجلឲ្យទូលព្រះបង្គំមានឱកាសសងសឹកឲ្យព្រះអង្គعليهم السلامជុំជាមួយអ៊ីម៉ាំមគ្គុទេសក៍ ដែលជាព្រះរាជវង្សព្រះអង្គعليهم السلام ដែលត្រឹមត្រូវ ដែលជាសច្ចការី

وَأَسْأَلُ اللهَ بِحَقِّكُمْ وَبِالشَّأْنِ الَّذِي لَكُمْ عِنْدَهُ أَنْ يُعْطِيَنِي بِمُصابِي بِكُمْ أَفْضَلَ مايُعْطِي مُصابًا بِمُصِيبَتِهِ ،

ទូលព្រះបង្គំសូមអល់ឡោះហ៍عزوجل ក្នុងនាមនៃព្រះរាជសិទ្ធិនិងព្រះរាជឋានៈព្រះអង្គعليهم السلامដែលអល់ឡោះហ៍عزوجلព្រះរាជទានឲ្យព្រះអង្គعليهم السلامនោះ សូមឲ្យអល់ឡោះហ៍عزوجل ព្រះរាជទានឲ្យទូលព្រះបង្គំនូវរង្វាន់ដែលបានមកពីទូលព្រះបង្គំកាន់ទុក្ខព្រះអង្គعليهم السلام គឺរង្វាន់ដែលប្រសើរបំផុតដែលអល់ឡោះហ៍عزوجلព្រះរាជទានឲ្យអ្នកកាន់ទុក្ខ

مُصِيبَةً ما أَعْظَمَها وَأَعْظَمَ رَزِيَّتَها فِي الْإِسْلامِ وَفِي جَمِيعِ السَّماواتِ وَالْأَرْضِ

នេះគឺការកាន់ទុក្ខធំបំផុត ដែលបណ្ដាលឲ្យមានការសោកសៅធំបំផុតសម្រាប់សាសនាអ៊ីស្លាមនិងសម្រាប់មេឃនិងដីរួមគ្នា

اَللّٰهُمَّ اجْعَلْني فِي مَقامِي هَذا مِمَّنْ تَنالُهُ مِنْكَ صَلَواتٌ وَرَحْمَةٌ وَمَغْفِرَةٌ،

អល់ឡោះហ្ម៍﷿អឺយ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំបាននៅជុំជាមួយអស់បុគ្គលដែលព្រះអង្គ﷿ព្រះរាជទានព្រះពរជ័យ ព្រះមេត្តាធម៌ និងព្រះខមាទោសឲ្យ

اَللّٰهُمَّ اجْعَلْ مَحْيايَ مَحْيا مُحَمَّدٍ وَآلِ مُحَمَّدٍ وَمَماتي مَماتَ مُحَمَّدٍ وَآلِ مُحَمَّدٍ،

អល់ឡោះហ្ម៍﷿អឺយ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំបានរស់នៅដូចមូហាំម៉ាដ់ﷺនិងព្រះរាជកុលដ្ឋាន(عليهم السلام)របស់មូហាំម៉ាដ់ﷺបានរស់នៅដែរ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំបានស្លាប់ដូចមូហាំម៉ាដ់ﷺនិងព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ់ﷺបានចូលទិវង្គតដែរ

اللَّهُمَّ إِنَّ هَذا يَوْمٌ تَبَرَّكَتْ بِهِ بَنُو أُمَيَّةَ وَابْنُ آكِلَةِ الْأَكْبادِ اللَّعِينُ ابْنُ اللَّعِينِ عَلى لِسانِكَ وَلِسانِ نَبِيِّكَ صَلَّى اللهُ عَلَيْهِ وَآلِهِ فِي كُلِّ مَوْطِنٍ وَمَوْقِفٍ وَقَفَ فِيهِ نَبِيُّكَ صَلَّى اللهُ عَلَيْهِ وَآلِهِ

អល់ឡោះហ្ម៍﷿អឺយ នេះគឺថ្ងៃអបអរសាទរសម្រាប់ពួកបានី-អ៊ូម៉ៃយ៉ាស់ សម្រាប់ពួកកូនចៅរបស់នារីស៊ីថ្លើម សម្រាប់បុរសត្រូវបណ្ដាសា កូនរបស់បុរសត្រូវបណ្ដាសា ត្រូវបណ្ដាសាដោយមាត់ព្រះអង្គ﷿ ដោយមាត់ព្រះសាស្ដាﷺព្រះអង្គ﷿ នៅគ្រប់ទីកន្លែង នៅគ្រប់ទីសំណាក់ដែលព្រះសាស្ដាﷺព្រះអង្គ﷿បានសំចតឈប់

اللَّهُمَّ الْعَنْ أَبا سُفيانَ وَمُعاوِيَةَ

អល់ឡោះហ្ម៍﷿អឺយ សូមព្រះអង្គ﷿ដាក់



عَنِّي كَيْدَهُ وَمَكْرَهُ وَبَأْسَهُ وَأَمانِيَّهُ وَامْنَعْهُ عَنِّي كَيْفَ شِئْتَ وَأَنَّى شِئْتَ ،

សូមព្រះអង្គ﷿សងបុគ្គលនោះវិញ បុគ្គលណាធ្វើឧបាយកលដាក់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ﷿ធ្វើឧបាយកលដាក់បុគ្គលនោះវិញ សូមព្រះអង្គ﷿បំបែរឆ្ងាយពីទូលព្រះបង្គំជាខ្ញុំនូវឧបាយកលរបស់បុគ្គលនោះ ការបោកបញ្ឆោតរបស់បុគ្គលនោះ អំពើឃោរឃៅរបស់បុគ្គលនោះ ផែនការក្បត់របស់បុគ្គលនោះ។ សូមព្រះអង្គ﷿រុញច្រានបុគ្គលនោះឆ្ងាយពីទូលព្រះបង្គំជាខ្ញុំដោយវិធីណាមួយស្រេចតែព្រះអង្គ﷿ ពីខាងណាមួយស្រេចតែលើព្រះអង្គ﷿

اللَّهُمَّ اشْغَلْهُ عَنِّي بِفَقْرٍ لا تَجْبُرُهُ وَبِبَلاءٍ لا تَسْتُرُهُ وَبِفاقَةٍ لا تَسُدُّها وَبِسُقْمٍ لا تُعافِيهِ وَذُلٍّ لا تُعِزُّهُ وَبِمَسْكَنَةٍ لا تَجْبُرُها ،

អល់ឡោះហ្ម៍﷿អឺយ សូមព្រះអង្គ﷿ធ្វើឲ្យបុគ្គលនោះរវល់តែនៅឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ នៅក្នុងភាពក្រីក្រដែលព្រះអង្គ﷿មិនធ្វើឲ្យបានរួចផុតទេ នៅក្នុងទុក្ខដែលព្រះអង្គ﷿មិនធ្វើឲ្យបានធូរស្រាលទេ នៅក្នុងការខ្វះខាតដែលព្រះអង្គ﷿មិនជួយដោះស្រាយទេ នៅក្នុងជម្ងឺដែលព្រះអង្គ﷿មិនធ្វើឲ្យជាទេ នៅក្នុងភាពអាប់ឱនដែលព្រះអង្គ﷿មិនធ្វើឲ្យបានភ្លឺស្វាងឡើងទេ នៅក្នុងភាពទ័លក្រដែលព្រះអង្គ﷿មិនឲ្យចេញផុតទេ

اللَّهُمَّ اضْرِبْ بِالذُّلِّ نَصْبَ

អល់ឡោះហ្ម៍﷿អឺយ សូមព្រះអង្គ﷿ឲ្យ

وَجَوْرَ مَنْ أَخافُ جَوْرَهُ وَسُلْطانَ مَنْ أَخافُ سُلْطانَهُ

[សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី]អំពើអយុត្តិធម៌របស់បុគ្គលដែលប្រកបដោយអំពើអយុត្តិធម៌ដែលទូលព្រះបង្គំជាខ្ញុំខ្លាច [សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី]ការសង្កត់សង្កិនរបស់បុគ្គលដែលប្រកបដោយអំពើសង្កត់សង្កិន ដែលទូលព្រះបង្គំជាខ្ញុំខ្លាច [សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី]អំណាចរបស់បុគ្គលដែលមានអំណាចដែលទូលព្រះបង្គំជាខ្ញុំខ្លាច

وَكَيْدَ مَنْ أَخافُ كَيْدَهُ وَمَقْدُرَةَ مَنْ أَخافُ مَقْدُرَتَهُ عَلَيَّ وَتَرُدَّ عَنِّي كَيْدَ الْكَيَدَةِ وَمَكْرَ الْمَكَرَةِ.

[សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី]ការបោកបញ្ឆោតរបស់បុគ្គលដែលមានការបោកបញ្ឆោតដែលទូលព្រះបង្គំជាខ្ញុំខ្លាច [សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី]ឥទ្ធិពលរបស់បុគ្គលដែលមានឥទ្ធិពលដែលទូលព្រះបង្គំជាខ្ញុំខ្លាច សូមឲ្យការបោកបញ្ឆោតរបស់បុគ្គលដែលមានការបោកបញ្ឆោតឃ្លាតឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ [សូមឲ្យ]ឧបាយកលរបស់បុគ្គលដែលមានឧបាយកល[ឃ្លាតឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ] ។

اللّٰهُمَّ مَنْ أَرادَنِي فَأَرِدْهُ وَمَنْ كادَنِي فَكِدْهُ وَاصْرِفْ

អល់ឡោះហ៍ﷻអឺយ បុគ្គលណាដែលមានបំណងអាក្រក់មកលើទូលព្រះបង្គំជាខ្ញុំ



وَيَزِيدَ بْنَ مُعاوِيَةَ عَلَيْهِمْ مِنْكَ اللَّعْنَةُ أَبَدَ الْآبِدِينَ ،

បណ្ដាសាអាប៊ូ ស៊ុហ្វយ៉ាន មូអាវីយ៉ាស់ និងយ៉ាស៊ីដ្ឋ កូនរបស់មូអាវីយ៉ាស់ ។ សូមឲ្យព្រះបណ្ដាសាព្រះអង្គﷻពើបពះលើពួកវារៀងរហូតអនន្ត

وَهَذا يَوْمٌ فَرِحَتْ بِهِ آلُ زِيادٍ وَآلُ مَرْوانَ بِقَتْلِهِمُ الْحُسَيْنَ صَلَواتُ اللهِ عَلَيْهِ

នេះគឺថ្ងៃដែលត្រកូលស៊ីយ៉ាដ្ឋនិងត្រកូលម៉ារវ៉ានត្រេកអរដែលបានប្រហារអាល់-ហ៊ូសៃន៍ សូមអល់ឡោះហ៍ﷻជូនពរជ័យដល់ព្រះអង្គ

اللّٰهُمَّ فَضاعِفْ عَلَيْهِمُ اللَّعْنَ مِنْكَ وَالْعَذابَ الأَلِيمِ

អល់ឡោះហ៍ﷻអឺយ សូមព្រះអង្គﷻដាក់បណ្ដាសាពួកវាឲ្យច្រើនលើសដើម ដាក់ទណ្ឌកម្មពួកវាយ៉ាងឈឺចាប់បំផុត

اللّٰهُمَّ إِنِّي أَتَقَرَّبُ إِلَيْكَ فِي هَذا الْيَوْمِ وَفِي مَوْقِفِي هَذا وَأَيامِ حَياتِي بِالْبَرَائَةِ مِنْهُمْ وَاللَّعْنَةِ عَلَيْهِمْ وَبِالْمُوالاةِ لِنَبِيِّكَ وَآلِ نَبِيِّكَ عَلَيهِ وَ عَلَيْهِمُ السَّلامُ.

អល់ឡោះហ៍ﷻអឺយ ទូលព្រះបង្គំជាខ្ញុំសូមចូលក្បែរព្រះអង្គﷻក្នុងថ្ងៃនេះ នាទីនេះនិងរៀងរាល់ថ្ងៃអស់មួយជីវិតទូលព្រះបង្គំជាខ្ញុំ ដោយបដិសេធពួកវាដោយប្រទេចផ្ដាសាពួកវា ដោយគោរពស្រឡាញ់ព្រះសាស្ដាﷺព្រះអង្គﷻនិងព្រះរាជវង្សានុវង្សរបស់ព្រះសាស្ដាព្រះអង្គﷻ សូមសិរីសួស្ដីកើតមានដល់ព្រះអង្គﷺនិងព្រះអង្គទាំងឡាយعليهم السلام ។

ثم تقول مائة مرة :

បន្ទាប់ពីនោះចូរសូត្រ ១០០ ដងថា៖

اللَّهُمَّ الْعَنْ أَوَّلَ ظالِمٍ ظَلَمَ حَقَّ مُحَمَّدٍ وَآلِ مُحَمَّدٍ وَآخِرَ تابِعٍ لَهُ عَلَى ذٰلِكَ ،

អល់ឡោះហ្វ៍عزوجلអឺយ សូមព្រះអង្គعزوجلដាក់បណ្ដាសាបុគ្គលសង្កត់សង្កិនមុនគេបង្អស់ដែលបានរំលោភសិទ្ធិមូហ៊ាំម៉ាដ្ឋ់صلى الله عليه وآله وسلمនិងព្រះរាជកុលដ្ឋានعليهم السلامរបស់មូហ៊ាំម៉ាដ្ឋ់صلى الله عليه وآله وسلم និងបុគ្គល[សង្កត់សង្កិន]ក្រោយគេដែលប្រព្រឹត្តតាមគន្លងនេះដែរ

اللَّهُمَّ الْعَنِ الْعِصابَةَ الَّتِي جاهَدَتِ الْحُسَيْنَ وَشايَعَتْ وَبايَعَتْ وَتابَعَتْ عَلَى قَتْلِهِ اللَّهُمَّ الْعَنْهُمْ جَمِيعًا.

អល់ឡោះហ្វ៍عزوجلអឺយ សូមព្រះអង្គعزوجلដាក់បណ្ដាសាបនដែលបានប្រយុទ្ធតទល់អាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ដែលបានចូលដៃក្នុងការប្រហារព្រះអង្គصلوات الله عليه والسلام ដែលបានសន្យាប្រហារព្រះអង្គصلوات الله عليه والسلام ដែលបានមូលមតិគ្នាប្រហារព្រះអង្គصلوات الله عليه والسلام ។ សូមអល់ឡោះហ្វ៍عزوجلដាក់បណ្ដាសាពួកវាទាំងអស់គ្នានេះ ។

ثم تقول مائة مرة :

រួចហើយចូរសូត្រ ១០០ ដងថា៖

السَّلامُ عَلَيْكَ يا أَبا عَبْدِ اللهِ وَعَلَى الأَرْواحِ الَّتِي

សូមព្រះសិរីសួស្ដីអល់ឡោះហ្វ៍عزوجلកើតមានដល់ព្រះអង្គصلوات الله عليه والسلام ឱ អាប៊ូអាប់ឌុលឡោះហ្វ៍صلوات الله عليه والسلام និងកើតមានដល់



وَأَنْ تَكْشِفَ عَنِّي غَمِّي وَهَمِّي وَكَرْبِي وَتَكْفِيَنِي الْمُهِمَّ مِنْ أُمُورِي وَتَقْضِيَ عَنِّي دَيْنِي

សូមឲ្យទូលព្រះបង្គំជាខ្ញុំអស់បារម្ភ អស់កង្វល់ អស់ទុក្ខព្រួយ សូមឲ្យជួយដោះស្រាយកិច្ចការសំខាន់ៗរបស់ទូលព្រះបង្គំជាខ្ញុំ សូមឲ្យជួយលុបលាងបំណុលទូលព្រះបង្គំជាខ្ញុំ

وَتُجِيرَنِي مِنَ الْفَقْرِ وَتُجِيرَنِي مِنَ الْفاقَةِ وَتُغْنِيَنِي عَنِ الْمَسْأَلَةِ إِلَى الْمَخْلُوقِينَ،

សូមឲ្យជួយការពារទូលព្រះបង្គំជាខ្ញុំពីភាពក្រីក្រ សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីការទ័លក្រ សូមឲ្យទូលព្រះបង្គំជាខ្ញុំអាចចៀសវាងការសូមពីសត្វលោក

وَتَكْفِيَنِي هَمَّ مَنْ أَخافُ هَمَّهُ وَعُسْرَ مَنْ أَخافُ عُسْرَهُ وَحُزُونَةَ مَنْ أَخافُ حُزُونَتَهُ وَشَرَّ مَنْ أَخافُ شَرَّهُ

សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីបារម្ភរបស់បុគ្គលដែលមានបារម្ភដែលទូលព្រះបង្គំជាខ្ញុំខ្លាច សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីឧបសគ្គរបស់បុគ្គលដែលមានឧបសគ្គដែលទូលព្រះបង្គំជាខ្ញុំខ្លាច សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីសេចក្ដីលំបាករបស់បុគ្គលដែលមានសេចក្ដីលំបាកដែលទូលព្រះបង្គជាខ្ញុំខ្លាច សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីហេតុការណ៍អាក្រក់របស់បុគ្គលដែលមានហេតុការណ៍អាក្រក់ដែលទូលព្រះបង្គំជាខ្ញុំខ្លាច

وَمَكْرَ مَنْ أَخافُ مَكْرَهُ وَبَغْيَ مَنْ أَخافُ بَغْيَهُ

[សូមឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពី] ឧបាយកលរបស់បុគ្គលដែលមានឧបាយកលដែលទូលព្រះបង្គំជាខ្ញុំខ្លាច

وَأَعْزِمُ عَلَيْكَ ،

ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គ(عزّوجلّ) អង្វរករព្រះអង្គ(عزّوجلّ)យ៉ាងម៉ឺងម៉ាត់

وَبِالشَّأْنِ الَّذِي لَهُمْ عِنْدَكَ وَبِالْقَدْرِ الَّذِي لَهُمْ عِنْدَكَ وَبِالَّذِي فَضَّلْتَهُمْ عَلَى الْعالَمِينَ

ក្នុងនាមបុណ្យស័ក្តិឧត្តមនិងគុណសម្បត្តិដែលវរជនទាំងនេះ(عليهم السلام)មាន សម្រាប់ព្រះអង្គ(عزّوجلّ)នោះ ហើយដោយសារអ្វីទាំងនេះឯងដែលព្រះអង្គ(عزّوجلّ)សព្វព្រះហឫទ័យវរជនទាំងនេះ(عليهم السلام)លើសអស់សត្វលោកឯទៀត

وَبِاسْمِكَ الَّذِي جَعَلْتَهُ عِنْدَهُمْ وَبِهِ خَصَصْتَهُمْ دُونَ الْعالَمِينَ

និងក្នុងព្រះរាជនាមព្រះអង្គ(عزّوجلّ) ដែលព្រះអង្គ(عزّوجلّ)ទុកដាក់នៅឯវរជនទាំងនេះ(عليهم السلام) ព្រះអង្គ(عزّوجلّ)ប្រគល់ព្រះរាជនាមនេះឲ្យទៅវរជនទាំងនេះ(عليهم السلام)ដាច់មុខ ជាជាង[ប្រគល់ឲ្យទៅ]សត្វលោកឯទៀត

وَبِهِ أَبَنْتَهُمْ وَأَبَنْتَ فَضْلَهُمْ مِنْ فَضْلِ الْعالَمِينَ حَتَّى فاقَ فَضْلُهُمْ فَضْلَ الْعالَمِينَ جَمِيعًا ،

អាស្រ័យព្រះរាជនាមនេះឯង ព្រះអង្គ(عزّوجلّ) ធ្វើឲ្យវរជនទាំងនេះ(عليهم السلام)លេចត្រដែតឡើង ហើយព្រះអង្គ(عزّوجلّ)ធ្វើឲ្យគុណសម្បត្តិវរជនទាំងនេះ(عليهم السلام)លេចត្រដែតឡើងពីចំណោមគុណសម្បត្តិអស់សត្វលោកឯទៀត ដល់ថ្នាក់គុណសម្បត្តិវរជនទាំងនេះ(عليهم السلام)រំលងហួសគុណសម្បត្តិអស់សត្វលោកឯទៀត

أَسْأَلُكَ أَنْ تُصَلِّيَ عَلَى مُحَمَّدٍ وَآلِ مُحَمَّدٍ

ទូលព្រះបង្គំជាខ្ញុំសូមឲ្យព្រះអង្គ(عزّوجلّ)ប្រសិទ្ធពរជ័យដល់មូហាំម៉ាដ(صلى الله عليه وآله وسلم)និងដល់ព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ(صلى الله عليه وآله وسلم)



حَلَّتْ بِفِنائِكَ ،

វិញ្ញាណទាំងឡាយដែលនៅលើទីធ្លាព្រះអង្គ(صلوات الله عليه والسلام) ។

عَلَيْكَ مِنِّي سَلامُ اللهِ أَبَدًا مابَقِيتُ وَبَقِيَ اللَّيْلُ وَالنَّهارُ وَلا جَعَلَهُ اللهُ آخِرَ الْعَهْدِ مِنِّي لِزِيارَتِكُمْ

ចូរកើតមានដល់ព្រះអង្គ(صلوات الله عليه والسلام) ពីទូលបង្គំនូវព្រះសិរីសួស្តីអល់ឡោះហ្វ៍(عزّوجلّ) ជានិច្ចអនន្ត ដរាបណាទូលព្រះបង្គំមានជីវិត ដរាបណានៅមានយប់និងថ្ងៃ ។ សូមអល់ឡោះហ្វ៍(عزّوجلّ)កុំឲ្យលើកនេះជាលើកចុងក្រោយបង្អស់ដែលទូលព្រះបង្គំស៊ីរ៉ាស់ព្រះអង្គ(صلوات الله عليه والسلام) ។

اَلسَّلامُ عَلَى الْحُسَيْنِ وَعَلَى عَلِيِّ بْنِ الْحُسَيْنِ وَعَلَى اَوْلادِ الْحُسَيْنِ وَعَلَى اَصْحابِ الْحُسَيْنِ،

សូមសិរីសួស្តីកើតមានដល់ អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) ដល់អាលី(صلوات الله عليه والسلام) រាជបុត្ររបស់អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) ដល់រាជបុត្រាបុត្រីទាំងឡាយ(عليهم السلام)របស់អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) និងដល់បណ្តាសាវកទាំងឡាយរបស់អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) ។

ثم تقول :

រួចហើយ ចូរសូត្រថា៖

اللَّهُمَّ خُصَّ أَنْتَ أَوَّلَ ظالِمٍ بِاللَّعْنِ مِنِّي وَأَبْدَأْ بِهِ

អល់ឡោះហ្វ៍(عزّوجلّ)អើយ សូមព្រះអង្គ(عزّوجلّ) ឧទ្ទិសបណ្តាសាទូលបង្គំចំពោះបុគ្គលសង្កត់សង្កិនទីមួយជាពិសេស ហើយចាប់ផ្តើម

أَوَّلًا ثُمَّ الْعَنْ الثَّانِيَ وَالثَّالِثَ وَالرَّابِعَ ،

លើបុគ្គលនេះមុនគេ ។ បន្ទាប់ពីនោះ សូមព្រះអង្គﷻដាក់បណ្ដាសាបុគ្គលទីពីរ បុគ្គលទីបី និងបុគ្គលទីបួន ។

اللَّهُمَّ الْعَنْ يَزِيدَ خامِسًا وَالْعَنْ عُبَيْدَ اللهِ بْنَ زِيادٍ وَابْنَ مَرْجانَةَ وَعُمَرَ بْنَ سَعْدٍ وَشِمْرًا وَآلَ أَبِي سُفْيانَ وَآلَ زِيادٍ وَآلَ مَرْوانَ إِلَى يَوْمِ الْقِيامَةِ.

សូមអល់ឡោះហ៍ﷻដាក់បណ្ដាសាយ៉ាស៊ីដបុគ្គលទីប្រាំ ហើយដាក់បណ្ដាសាអ៊ូបៃឌុលឡោះហ៍ ប៊ិន ស៊ីយ៉ាដ, ប៊ិន ម៉ារយ៉ាណាស់, អ៊ូម៉ារ ប៊ិន សាក់ដ៍, ស្ស៊ីមរ៍, ត្រកូលអាប៊ូ ស៊ុហ្វយ៉ាន, ត្រកូលស៊ីយ៉ាដ់ និងត្រកូលម៉ារវ៉ានរហូតដល់ថ្ងៃរស់ឡើងវិញ ។

ثم تسجد وَتقول :

រួចហើយ ចូរក្រាបប្រណិប័តន៍ (គឺស៊ូយូដ) ហើយសូត្រថា៖

اللَّهُمَّ لَكَ الْحَمْدُ حَمْدَ الشَّاكِرِينَ لَكَ عَلَى مُصابِهِمْ ، الْحَمْدُ لِلَّهِ عَلَى عَظِيمِ رَزِيَّتِي ،

អល់ឡោះហ៍ﷻអើយ សូមថ្វាយសេចក្ដីសរសើរចំពោះព្រះអង្គﷻ គឺសេចក្ដីសរសើររបស់បណ្ដាអ្នកអរព្រះគុណព្រះអង្គﷻដែលកាន់ទុក្ខ ។ សូមថ្វាយសេចក្ដីសរសើរចំពោះព្រះអង្គﷻសម្រាប់ការកាន់ទុក្ខធំរបស់ទូលព្រះបង្គំជាខ្ញុំ ។

اللَّهُمَّ ارْزُقْنِي شَفاعَةَ

សូមអល់ឡោះហ៍ﷻឲ្យទូលព្រះបង្គំជាខ្ញុំទទួលបាននូវការជួយធ្វើអន្តរាគមន៍របស់



الرَّغَباتِ يا كافِيَ الْمُهِمَّاتِ ،

ដែលការពារឲ្យចាកផុតពីសេចក្ដីបារម្ភ

يا مَنْ يَكْفِي مِنْ كُلِّ شَىْءٍ وَلَا يَكْفِي مِنْهُ شَيْءٌ فِي السَّماوَاتِ وَالْاَرْضِ،

ឱព្រះដែលមិនត្រូវការអ្វីឡើយ ដែលសព្វសារពើនៅលើមេឃនិងលើផែនដីត្រូវការជាចាំបាច់ មិនអាចចោលបានឡើយ

أَسْأَلُكَ بِحَقِّ مُحَمَّدٍ خاتَمِ النَّبِيِّينَ وَعَلِيٍّ أَمِيرِ الْمُؤْمِنِينَ وَبِحَقِّ فاطِمَةَ بِنْتِ نَبِيِّكَ وَبِحَقِّ الْحَسَنِ وَالْحُسَيْنِ

ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គﷻ ក្នុងនាមព្រះរាជសិទ្ធិរបស់មូហាំម៉ាដ់ﷺ ព្រះសាស្ដាចុងក្រោយបង្អស់ និងអាលី صلوات الله عليه والسلام អាមីរុល-មុមីនីន ក្នុងនាមព្រះរាជសិទ្ធិរបស់ហ្វាទីម៉ាស់ سلام الله عليها ព្រះរាជបុត្រីរបស់ព្រះសាស្ដារបស់ព្រះអង្គﷻ ក្នុងនាមព្រះរាជសិទ្ធិរបស់អាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហូសៃន៍ صلوات الله عليه والسلام

فَإِنِّي بِهِمْ أَتَوَجَّهُ إِلَيْكَ فِي مَقامِي هَذَا وَبِهِمْ أَتَوَسَّلُ وَبِهِمْ أَتَشَفَّعُ إِلَيْكَ

ដូច្នេះ តាមរយៈវរជនទាំងនេះ عليهم السلام ទូលព្រះបង្គំជាខ្ញុំបែរមករកព្រះអង្គﷻនាទីនេះ ដែលជាទីកន្លែងរបស់ទូលព្រះបង្គំជាខ្ញុំ តាមរយៈវរជនទាំងនេះ عليهم السلام ទូលព្រះបង្គំជាខ្ញុំសូមអង្វរព្រះអង្គﷻ តាមរយៈវរជនទាំងនេះ عليهم السلام ទូលព្រះបង្គំជាខ្ញុំសូមឲ្យជួយធ្វើអន្តរាគមន៍ចំពោះព្រះអង្គﷻ

وَبِحَقِّهِمْ أَسْأَلُكَ وَأُقْسِمُ

ក្នុងនាមព្រះរាជសិទ្ធិវរជនទាំងនេះ عليهم السلام

| | |
|---|---|
| ឱព្រះដែលគេមិនអាចលាក់បាំងអ្វីបានឡើយ ឱព្រះដែលមិនច្រឡំសម្លេងទាំងឡាយឡើយ(ច្រឡំបានសេចក្ដីថាចាំសម្លេងអ្នក បួងសួងមិនបាន ព្រោះលាយឡំគ្នា) | وَيا مَنْ لَا يَخْفى عَلَيْهِ خافِيَةٌ ، يا مَنْ لَا تَشْتَبِهُ عَلَيْهِ الْاَصْواتُ |
| ឱព្រះដែលមិនច្រឡំសេចក្ដីត្រូវការឡើយ (ច្រឡំបានសេចក្ដីថាចំណាំសេចក្ដីត្រូវរបស់សត្វលោកមិន បានព្រោះលាយឡំគ្នា) ឱព្រះដែលមិនធុញទ្រាន់ព្រះហឫទ័យឡើយ ដោយសារគេទទូចសូមឥតដាច់ | وَيا مَنْ لَا تُغَلِّطُهُ الْحاجاتُ وَيا مَنْ لَا يُبْرِمُهُ إِلْحاحُ الْمُلِحِّينَ ، |
| ឱព្រះដែលតាមទាន់អ្វីៗដែលរួចរបូត ឱព្រះដែលប្រមូលផ្ដុំបានអ្វីៗដែលរាត់រាយ | يا مُدْرِكَ كُلِّ فَوْتٍ وَيا جامِعَ كُلِّ شَمْلٍ |
| ឱព្រះដែលធ្វើឲ្យវិញ្ញាណរស់ឡើងវិញក្រោយពីស្លាប់ ឱព្រះដែលប្រតិបត្តិកិច្ចការថ្មីរៀងរាល់ថ្ងៃ | وَيا بارِئَ النُّفُوسِ بَعْدَ الْمَوْتِ يا مَنْ هُوَ كُلَّ يَوْمٍ فِي شَأْنٍ ، |
| ឱព្រះដែលបំពេញតាមបំណង ឱព្រះដែលសម្រាលទុក្ខ | يا قاضِيَ الْحاجاتِ يا مُنَفِّسَ الْكُرُباتِ |
| ឱព្រះដែលប្រទានឲ្យនូវអ្វីដែលគេសូម ឱព្រះដែលប្រទានឲ្យតាមចំណង់ ឱព្រះ | يا مُعْطِيَ السُّؤُلَاتِ يا وَلِيَّ |



| | |
|---|---|
| អាល់-ហ៊ូសែន៍ صلوات الله عليه والسلام ក្នុងថ្ងៃទៅដល់[ព្រះអង្គ عز وجل] សូមព្រះអង្គ عز وجل ធ្វើឲ្យទូលព្រះបង្គំជាខ្ញុំស្មោះត្រង់ចំពោះព្រះអង្គ عز وجل មាំឡើងជុំជាមួយអាល់-ហ៊ូសែន៍ صلوات الله عليه والسلام និងបណ្ដាសាវករបស់អាល់-ហ៊ូសែន៍ صلوات الله عليه والسلام ដែលបានបូជាជីវិតដើម្បីអាល់-ហ៊ូសែន៍ សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ។ | الْحُسَيْنِ يَوْمَ الْوُرُودِ وَثَبِّتْ لِي قَدَمَ صِدْقٍ عِنْدَكَ مَعَ الْحُسَيْنِ وَأَصْحابِ الْحُسَيْنِ الَّذِينَ بَذَلُوا مُهَجَهُمْ دُونَ الْحُسَيْنِ عَلَيْهِ السَّلامُ. |

قال علقمة : قال الباقر عليه السلام : وإن استطعت أن تزوره في كل يوم بهذه الزيارة في دارك فافعل فلك ثواب جميع ذلك.

وروى محمد بن خالد الطيالسي عن سيف بن عميرة قال : خرجت مع صفوان بن مهران وجماعة من أصحابنا إلى الغري بعد ما خرج الصادق عليه السلام فسرنا من الحيرة إلى المدينة فلمّا فرغنا من الزيارة أي زيارة أمير المؤمنين عليه السلام صرف صفوان وجهه إلى ناحية أبي عبد الله عليه السلام فقال لنا : تزورون الحُسَين عليه السلام من هذا المكان من عند رأس أمير المؤمنين عليه السلام من هاهنا أومأ إليه الصادق عليه السلام وأنا معه.

قال سيف بن عميرة : فدعا صفوان بالزيارة التي رواها علقمة بن محمد الحضرمي عن الباقر عليه السلام في يوم عاشوراء ثم صلى ركعتين عند رأس أمير المؤمنين عليه السلام وودّع في دبرهما أمير المؤمنين عليه السلام وأومأ إلى الحُسَين صلوات الله عليه بالسلام مصرفاً بوجهه نحوه وودّع وكان مما دعا

دبرها :

អាល់-ក៏ម៉ាស់បានថា[អ៊ីម៉ាំ] អាល់-បាគៀរ صلوات الله عليه والسلام មានវចនៈថា៖ "បើលោកអាចស៊ីរ៉ាស់ព្រះអង្គ صلوات الله عليه والسلام រាល់ថ្ងៃបានដោយសូត្រឌូអាអ៊ុស៊ីយ៉ារ៉ាស់នេះនៅឯផ្ទះលោកបាន ចូរលោកស៊ីរ៉ាស់ទៅពីព្រោះលោកនឹងបានទទួលផលបុណ្យល្អ ។"

មូហាំម៉ាដ់ ប៊ិន ខ៉ូលិដ អាត់-ត៏យ៉ាលីស៊ីបានធ្វើសេចក្ដីរាយការណ៍មកពីសៃហ្វ៍ ប៊ិន អ៊ុម៉ៃរ៉ោះត៏ដែលបានឲ្យដឹងថា៖ "ខ្ញុំបានធ្វើដំណើរជាមួយស្វហ្វ៉ាន ប៊ិន មិស្រ៉ាននិងបណ្ដាសាវកមួយក្រុមទៅកាន់ណាយ៉ាហ្វ៍ បន្ទាប់ពី[អ៊ីម៉ាំ]អាស់-ស្វ៏ឌិក្ក صلوات الله عليه والسلام បានចាកចេញ ។ យើងបានចេញពីអាល់-ហ៊ីរ៉ោះត៏ទៅកាន់ទីក្រុង ។ លុះយើងបានធ្វើស៊ីយ៉ារ៉ាស់រួច គឺស៊ីយ៉ារ៉ាស់អាមីរុល-មុមីនីន صلوات الله عليه والسلام ស្វហ្វ៉ានបានបែរមុខទៅរកអាប៊ូ អាប់ឌុលឡោះហ្វ៍ ហើយប្រាប់យើងថា៖ "យើងស៊ីរ៉ាស់ អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ពីកន្លែងនេះពីខាងក្បាល[ផ្នូរ]អាមីរុល-មុមីនីន صلوات الله عليه والسلام ។ ពីកន្លែងនេះឯងដែលអាស់-ស្វ៏ឌិក្ក صلوات الله عليه والسلام បានគំនាប់ព្រះអង្គ صلوات الله عليه والسلام កាលនោះខ្ញុំនៅជុំមួយព្រះអង្គ صلوات الله عليه والسلام ។" ស្វហ្វ៉ានបានបួងសួងអល់ឡោះហ្វ៍ عز وجل ដោយសូត្រស៊ីយ៉ារ៉ាស់ដែលអាល់-ក៏ម៉ាស់ ប៊ិន មូហាំម៉ាដ់ អាល់-ហាដ់រ៉មីទទួលបានមកពី[អ៊ីម៉ាំ] អាល់-បាគៀរ صلوات الله عليه والسلام ថ្ងៃអាស៊ូរ៉អ៊ុ ។ បន្ទាប់មក លោកបានស្វ៏ឡាត់ពីរ៉ក់អាត់នៅក្បែរក្បាល[ផ្នូរ]អាមីរុល-មុមីនីន صلوات الله عليه والسلام ។ រួចហើយលោកបានគោរពលាអាមីរុល-មុមីនីន صلوات الله عليه والسلام ។ បន្ទាប់ពីនោះ លោកបានគំនាប់[អ៊ីម៉ាំ]អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ដោយឲ្យសាឡាមព្រះអង្គ صلوات الله عليه والسلام ដោយបែរមុខទៅរកទិសព្រះអង្គ صلوات الله عليه والسلام ហើយបានគោរពលាព្រះអង្គ صلوات الله عليه والسلام ។

ស្វ៏ឡាត់ពីរ៉ក់អាត់រួចហើយ លោកបានសូត្រឌូអាអ៊ុដូចតទៅ (ដែលហៅថាឌូអាអ៊ុ អាល់ក៏ម៉ាស់) គឺ៖



| | |
|---|---|
| يا اللهُ يا اللهُ يا اللهُ يا مُجِيبَ دَعْوَةِ الْمُضْطَرِّينَ يا كاشِفَ كُرَبِ الْمَكْرُوبِينَ | អល់ឡោះហ្វ៍ عز وجل អើយ អល់ឡោះហ្វ៍ عز وجل អើយ អល់ឡោះហ្វ៍ عز وجل អើយ ឱព្រះដែលឆ្លើយតបបុគ្គលតែលតោល ឱព្រះដែលសម្រាលទុក្ខអ្នកមានទុក្ខ |
| يا غِياثَ الْمُسْتَغِيثِينَ يا صَرِيخَ الْمُسْتَصْرِخِينَ ، | ឱព្រះដែលសង្គ្រោះបណ្ដាអ្នករងគ្រោះ ។ ឱព្រះដែលជួយបណ្ដាអ្នកសូមជំនួយ ។ |
| وَيا مَنْ هُوَ أَقْرَبُ إِلَيَّ مِنْ حَبْلِ الْوَرِيدِ | ឱព្រះដែលនៅជិតទូលព្រះបង្គំជាខ្ញុំជាងសរសៃបំពង់កទៅទៀត |
| وَيا مَنْ يَحُولُ بَيْنَ الْمَرْءِ وَقَلْبِهِ | ឱព្រះដែលនៅត្រង់ចន្លោះមនុស្សនិងបេះដូងមនុស្ស |
| وَيا مَنْ هُوَ بِالْمَنْظَرِ الْأَعْلَى وَبالْأُفُقِ الْمُبِينِ | ឱព្រះដែលនៅឯទីខ្ពស់បំផុត និងនៅឯមេឃមណ្ឌលច្បាស់ |
| وَيا مَنْ هُوَ الرَّحْمَنُ الرَّحِيمُ عَلَى الْعَرْشِ اسْتَوَى | ឱព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ដែលគ្រងព្រះរាជបល្ល័ង្ករុងរឿង |
| وَيا مَنْ يَعْلَمُ خائِنَةَ الْأَعْيُنِ وَما تُخْفِي الصُّدُورُ | ឱព្រះដែលស្គាល់ខ្សែភ្នែកក្បត់ និងអ្វីៗដែលលាក់បាំងនៅក្នុងទ្រូង |